សប្តាហ៍ទី 33

ព្រះយេស៊ូស្រឡាញ់ក្មេងតូចៗ

ព្រះយេស៊ូស្រឡាញ់ពួកយើងខ្លាំងណាស់ទ្រង់បានស្វាគមន៍ក្មេងៗ និងប្រទានពរដល់ពួកគេ!
ចូរពួកយើងអរព្រះគុណព្រះយេស៊ូសម្រាប់ក្តីស្រឡាញ់របស់ទ្រង់!

រឿងក្នុងព្រះគម្ពីរ

មនុស្សម្នានាំក្មេងតូចៗមករកព្រះយេស៊ូ។ ពួកសិស្សបានព្យាយាមឃាត់ពួកគេ ប៉ុន្តែព្រះយេស៊ូមានព្រះបន្ទូលថា៖

«ទុកឲ្យក្មេងតូចៗមករកខ្ញុំចុះ កុំឃាត់វាឡើយ ដ្បិតមានតែអ្នកមានចិត្តដូចក្មេងៗទាំងនេះប៉ុណ្ណោះ ដែលចូលក្នុងព្រះរាជ្យ*នៃស្ថានបរមសុខបាន» (ម៉ាកុស 10:14)

ព្រះយេស៊ូស្រឡាញ់ក្មេងតូចៗ ទ្រង់បានឱបពួកគេ ប្រទានពរពួកគេ និងស្វាគមន៍ពួកគេដោយក្តីស្រឡាញ់ដ៏ធំរបស់ទ្រង់។

ចូរពួកយើងចងចាំ និងអរព្រះគុណព្រះយេស៊ូសម្រាប់ក្តីស្រឡាញ់ទ្រង់!

សមិទ្ធផលសម្រេច

ពេលប្រើដីឥដ្ឋ	ពេលអត់ប្រើដីឥដ្ឋ
	

ព្រះយេស៊ូបង្កើតខ្ញុំយ៉ាងពិសេស ហើយស្រឡាញ់ខ្ញុំខ្លាំងណាស់!
ចូរទុកសេចក្តីស្រឡាញ់របស់ព្រះយេស៊ូក្នុងដួងចិត្តរបស់យើង
ហើយគួរទម្រង់មុខរបស់យើង ដើម្បីបង្ហាញក្តីស្រឡាញ់ទ្រង់!

វត្ថុបំណង

- ចងចាំថាព្រះយេស៊ូស្រឡាញ់ក្មេងតូចៗ
- បង្ហាញ និងឱ្យតម្លៃទម្រង់មុខរបស់ខ្លួនឯង
- ស្គាល់នូវក្តីអំណរតាមរយៈការបញ្ចេញគំនិតច្នៃប្រឌិត
- មានដួងចិត្តដឹងគុណចំពោះក្តីស្រឡាញ់របស់ព្រះយេស៊ូ។

សម្ភារៈ

ពេលប្រើដីឥដ្ឋ	ពេលអត់ប្រើដីឥដ្ឋ
ចានក្រដាស	ដីឥដ្ឋ	ក្រដាសរឹង
ស្នឹតរូបភ្នែក	ឧបករណ៍សូនដីឥដ្ឋ	ខ្មៅដៃពណ៌ កូល័រទៀន ហ្វឺត

របៀបធ្វើ

1. ការគូរទម្រង់មុខ
2. ការបង្កើតទម្រង់មុខដោយប្រើដីឥដ្ឋ
3. ការតុបតែងសក់
4. ការបន្ថែមចំណុចលម្អិត
5. ការគូរដោយមិនប្រើដីឥដ្ឋ
6. ការតុបតែងផ្នែកខាងក្រោយ








1. រៀបចំចានក្រដាស។ គួរទម្រង់មុខនៅលើវា។
2. បង្កើតភ្នែក ច្រមុះ មាត់ និងត្រចៀកដោយប្រើដីឥដ្ឋ។
3. បង្កើតសក់ដោយប្រើដីឥដ្ឋ ឬឧបករណ៍សូនដីឥដ្ឋ រួចបិទវាលើក្បាល។
4. បន្ថែមដីឥដ្ឋធ្វើថ្ពាល់ ឬ*អាវបន្ទាប់មកតុបតែងជាមួយពណ៌ ឬគ្រឿងតុបតែងតូចៗ។
5. រៀបចំក្រដាស គួររូបភ្នែក ច្រមុះ មាត់ ត្រចៀក និងសក់ដោយសេរី។
6. តុបតែងផ្នែកខាងក្រោយតាមអ្វីដែលអ្នកចូលចិត្តដើម្បីបញ្ចប់រូបភាព។

ការពង្រីកសកម្មភាព

- និយាយអំពីមូលហេតុដែលព្រះយេស៊ូស្រឡាញ់យើង។
- ស្វែងរករូបភាពមិត្តភក្តិ រួចបង្ហាញពីរបៀបដែលពួកយើងអាច
- ស្រឡាញ់គ្នាទៅវិញទៅមក។
- ឱបគ្រួសាររបស់អ្នកហើយនិយាយថា៖ «អរគុណដែលបានស្រឡាញ់ខ្ញុំ»។
- គូររូបគ្រួសាររបស់អ្នក ហើយបង្កើតជាស៊ុមរូបថត។
- សរសេរសំបុត្រថ្លែងអំណរគុណថ្វាយព្រះជាម្ចាស់។



Tip សម្រាប់គ្រូ

- កុមារអាចបញ្ចេញអារម្មណ៍របស់ពួកគេដោយសេរីតាមរយៈការធ្វើដីឥដ្ឋ និងការគូររូប។
- សូមសង្កេត និងណែនាំកុមារឱ្យស្គាល់ពីចំណុចខ្លាំងរបស់ពួកគេតាមរយៈការមើលផ្នែកមុខរបស់ខ្លួន។
- សូមផ្តល់សម្ភារៈចម្រុះដូចជា ដីឥដ្ឋ កូល័រទៀន ខ្មៅដៃពណ៌ និងហ្វឺត។
- សូមលើកទឹកចិត្តកុមារឱ្យមានអារម្មណ៍ថាទទួលបាននូវក្តីស្រឡាញ់ និងការឱ្យតម្លៃពេលដែលគេបង្ហាញទម្រង់មុខរបស់ពួកគេ។